01069951

D127

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 25 / 02 / 2015
ម៉ោង (Time/Heure): 09:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

គោរពជូន៖ **ឯកឧត្តម ឯម សំអាន**
រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
ប្រធានគណៈកម្មការសន្តិសុខសម្រាប់អ.វ.ត.ក

ឯកឧត្តម ឯម សំអាន ជាទីរាប់អាន!

ខ្ញុំឈ្មោះ Mark B. Harmon ហើយខ្ញុំគឺជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)។ គោលបំណងនៃលិខិតរបស់ខ្ញុំ គឺសូមជម្រាបជូន ឯកឧត្តម ថា កិច្ចខិតខំប្រឹងប្រែងដើម្បីឱ្យជនសង្ស័យពីររូបគឺ អ្នកស្រី អ៊ឹម ចែម និងលោក មាស មុត មកបង្ហាញខ្លួនលើកដំបូងនៅ អ.វ.ត.ក គឺមិនបានទទួលជោគជ័យទេ ហើយខ្ញុំមានបំណងចាត់វិធានការបន្ថែមទៀតដូចបានបង្ហាញជូនខាងក្រោមនេះដែលនឹងដាក់ជនសង្ស័យទាំងពីរឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។

កាលពីខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើជូនសហចៅក្រមស៊ើបអង្កេត សុំបើកការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ និង ០០៤។ ការស៊ើបអង្កេតដែលបានអនុវត្តរហូតមកដល់ថ្ងៃនេះ បង្ហាញថា មានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាដើម្បីដាក់ឱ្យស្ថិតក្រោមការពិនិត្យផ្នែកខ្លះទៅលើជនសង្ស័យទាំងពីរចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។

ទាក់ទងនឹងប្រវត្តិនីតិវិធី ទាំងអ្នកស្រី អ៊ឹម ចែម ទាំងលោក មាស មុត ត្រូវបានកោះហៅឱ្យមកតុលាការ ដើម្បីបង្ហាញខ្លួនលើកដំបូង ហើយជនសង្ស័យទាំងពីរ ដោយមានចេតនាមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់ទេ។ ដូច្នេះ ក៏មានចេញដីកានាំខ្លួនអ្នកស្រី អ៊ឹម ចែម នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ និងដីកានាំ

01069952



ខ្លួនលោក មាស មុត នៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤។ ភ្លាមៗបន្ទាប់ពីចេញដីកានាំខ្លួនទាំងនេះ នគរបាលយុត្តិធម៌របស់ប្រទេសកម្ពុជា ត្រូវបានស្នើសុំឱ្យអនុវត្តដីកាទាំងនេះអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនានានៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា លក្ខន្តិកៈសាលាក្តី និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក[1]។ រហូតមកដល់ថ្ងៃនេះ គ្មានដីកានាំខ្លួនណាមួយត្រូវបានអនុវត្តទេ។

នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ខ្ញុំបានជួបជាមួយលោកឧត្តមសេនីយ៍ ឡៅ សុឡេង ជាមន្ត្រីទំនាក់នគរបាលយុត្តិធម៌នៅ អ.វ.ត.ក ដើម្បីពិភាក្សាអំពីស្ថានភាពនៃដីកានាំខ្លួនអ្នកស្រី អ៊ឹម ចែម។ គាត់បានស្នើថា គួរមានការរៀបចំកម្មវិធីផ្សព្វផ្សាយនៅតំបន់ដែលជនសង្ស័យរស់នៅ ជាលក្ខខណ្ឌមួយដើម្បីអនុវត្តដីកានាំខ្លួន។ ខ្ញុំបានទទួលយកសំណើរបស់គាត់យ៉ាងស្មោក់ស្មើរ ហើយនៅចម្លោះរវាងថ្ងៃទី ១១ និងថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ កម្មវិធីផ្សព្វផ្សាយចំនួន ៩ ដាច់ដោយឡែកគ្នាបានរៀបចំធ្វើឡើងនៅខេត្តឧត្តរមានជ័យ ខេត្តបាត់ដំបង និងខេត្តប៉ៃលិន (រួមបញ្ចូលទាំងកម្មវិធីផ្សព្វផ្សាយមួយនៅសំឡូត ជាស្រុកដែលលោក មាស មុត ស្នាក់នៅ)។ ចាប់តាំងពីកម្មវិធីផ្សព្វផ្សាយទាំងនោះបានបញ្ចប់រួចមក គឺមានរយៈពេលជាងពីរខែហើយបានកន្លងផុត ហើយគ្មានដីកានាំខ្លួនណាមួយត្រូវបានអនុវត្តទេ។

ដោយសារមិនច្បាស់ថាតើដីកានាំខ្លួននឹងត្រូវអនុវត្តនៅពេលណានោះ ខ្ញុំបានសម្រេចថា ការពន្យារពេលបន្ថែមទៀតនឹងប៉ះពាល់ដល់ប្រយោជន៍យុត្តិធម៌ ពីព្រោះថាវាអាចប៉ះពាល់សិទ្ធិរបស់ជនសង្ស័យតាមមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[2] រួមបញ្ចូលទាំងសិទ្ធិចូលរួមការស៊ើបអង្កេត និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមិនសមស្របផងដែរ ហើយក៏ប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរដល់សិទ្ធិរបស់ជនរងគ្រោះ និងប្រជាជនកម្ពុជាដើម្បីទទួលបានយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ។ ដើម្បីការពារប្រយោជន៍របស់ជនសង្ស័យ និងប្រជាជនកម្ពុជា លើកកម្ពស់ការ

---

[1]មាត្រា២៥ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ(កិច្ចព្រមព្រៀង)។ មាត្រា ២៥ ថ្មីនៃច្បាប់ស្តីពីច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ(លក្ខន្តិកៈ) និងវិធាន ១៥ នៃវិធានផ្ទៃក្នុង។

[2]ប្រទេសកម្ពុជា បានចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩២។ ការអនុវត្តមាត្រា ១៤ នៃអនុសញ្ញានេះទៅលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក គឺមានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ១៣ នៃកិច្ចព្រមព្រៀង។

គោរពវិធាននៃច្បាប់ ធានាឱ្យ អ.វ.ត.ក ដំណើរការបានត្រឹមត្រូវ និងបញ្ចប់ការស៊ើបអង្កេតឱ្យបានទាន់ពេលវេលានោះ ខ្ញុំបានសម្រេចថា ដំណើរការនៃវិធានការដ៏ប្រុងប្រយ័ត្នតែមួយគត់ដោយសារគ្មានចំណាត់ការពីនគរបាលយុត្តិធម៌ គឺត្រូវដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*។ ខ្ញុំបានធ្វើសេចក្តីសម្រេចនេះយ៉ាងស្ទាក់ស្ទើរ ប៉ុន្តែមានអារម្មណ៍ថា ខ្ញុំគ្មានជម្រើសផ្សេងទៀតទេ។ ខ្ញុំយល់ឃើញជាមុនថា ការចាត់វិធានការនេះនឹងនាំឱ្យមានការចាប់អារម្មណ៍យ៉ាងច្រើនពីសាធារណជនទៅលើការខកខានរបស់នគរបាលយុត្តិធម៌ ដែលមិនបានអនុវត្តការទទួលខុសត្រូវរបស់ខ្លួនតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង។ ទោះយ៉ាងណា ការពន្យារពេលថែមទៀតគឺបង្កើតឱ្យមានហានិភ័យមិនអាចទទួលយកបានដែលអាចប៉ះពាល់ដល់សិទ្ធិរបស់ជនសង្ស័យ និងជនរងគ្រោះ ហើយនឹងនាំឱ្យមានការមិនគោរពទាំងវិធាននៃច្បាប់ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

អាស្រ័យហេតុនេះ ខ្ញុំសូមជូនដំណឹង ឯកឧត្តម ថា ប្រសិនបើគ្មានជនសង្ស័យណាម្នាក់ ឬគ្មានជនសង្ស័យទាំងពីរបានបង្ហាញខ្លួននៅតុលាការនៅមុនថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឬក៏ជនសង្ស័យមិនត្រូវបាននាំខ្លួនមកនៅត្រឹមកាលបរិច្ឆេទនោះទេ ខ្ញុំមានបំណងចេញដីកាសម្រេចជាសាធារណៈដាក់ជនសង្ស័យទាំងពីរឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*។

សូម ឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ។

Mark B. Harmon
សហចៅក្រមស៊ើបអង្កេតអន្តរជាតិ